**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**..០៤..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រែក្លាយមហាវិទ្យាល័យគរុកោសល្យ ទៅជាវិទ្យាស្ថានជាតិអប់រំ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពី ការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០២ ស្តីពី លក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធចាត់តាំង និងកំណត់តួនាទីរបស់សាកលវិទ្យាល័យភ្នំពេញ
- បានឃើញសំណើសុំ របស់ក្រសួងអប់រំ យុវជន និង កីឡា

www.pheakdeylaw.com

# សំរេច

**មាត្រា ១ :** ប្រែក្លាយមហាវិទ្យាល័យគរុកោសល្យ ទៅជាវិទ្យាស្ថានជាតិអប់រំ ( វ.ជ.អ ) និង ជាភាសាអង់គ្លេស ហៅថា National Institute of Education (NIE) ។ វិទ្យាស្ថាននេះ ស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ២ :** វិទ្យាស្ថានជាតិអប់រំ មានចក្ខុវិស័យកសាងធនធានមនុស្សបំរើឱ្យសេចក្តីត្រូវការ នៃការអភិវឌ្ឍន៍វិស័យអប់រំនៅក្នុងព្រះរាជាណាចក្រកម្ពុជា និង មានបេសកកម្មបណ្តុះបណ្តាល និងវិក្រឹត្យការគ្រូបង្រៀន អ្នកគ្រប់គ្រងអប់រំ មន្ត្រីអធិការកិច្ចអប់រំ និងអ្នកធ្វើផែនការអប់រំ និង ស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេសអប់រំ ដើម្បីរួមចំណែកអភិវឌ្ឍន៍ប្រទេស និង លើកស្ទួយអត្តសញ្ញាណជាតិ ។

**មាត្រា ៣ :** តួនាទី ភារកិច្ច កម្មវិធី និងកិរិតបណ្តុះបណ្តាល និង រចនាសម្ព័ន្ធរបស់វិទ្យាស្ថានជាតិអប់រំត្រូវកំណត់ដោយប្រកាសរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៤ :** វិទ្យាស្ថានជាតិអប់រំ មាន ២ដេប៉ាតឺម៉ង់គឺ : ដេប៉ាតឺម៉ង់អប់រំ និង ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ ។ ទៅអនាគត វិទ្យាស្ថាននេះ អាចបើកដេប៉ាតឺម៉ង់ ឬប្រភេទបណ្តុះបណ្តាលដទៃទៀតដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៥ :** វិទ្យាស្ថានជាតិអប់រំដឹកនាំដោយនាយកមួយរូបនិងនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**មាត្រា ៦ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចរៀង១ខ្លួនដើម្បីអនុវត្តតាមអនុក្រឹត្យនេះ ។

**មាត្រា ៨ :** អនុក្រឹត្យនេះ មានប្រសិទ្ធភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ

" <u>ដើម្បីមុខការ</u> "

- ដូចមាត្រា ៧ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com